# ភាពមិនស៊ីគ្នារវាងតម្រូវការអភិវឌ្ឍន៍របស់ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាស្រុក៖ លទ្ធផលពីសិក្ខាសាលាផ្សព្វផ្សាយឆ្នាំ២០១១[១]

## សេចក្ដីផ្ដើម

កម្មវិធីអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងកំណែទម្រង់សាធារណៈ (DGPSR) នៃវិទ្យាស្ថាន CDRI នៅថ្ងៃទី១៨-១៩ តុលា២០១១ បានរៀបចំឡើងនូវសិក្ខាសាលាលើកទី៣ដើម្បីចែករំលែកលទ្ធផលស្រាវជ្រាវ និងទទួលយកអនុសាសន៍ទាក់ទិននឹងបញ្ហាប្រឈម ក៏ដូចជាការរីកចម្រើននានា នៅក្នុងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ ដោយមានការចូលរួមពីមន្ត្រីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងអង្គការមិនមែនរដ្ឋាភិបាល ប្រមាណ ៣០០នាក់ អង្គសិក្ខាសាលាបានផ្ដោតការពិភាក្សាទៅលើប្រធានបទជាច្រើន ជុំវិញបញ្ហាអភិបាលកិច្ច និងការអភិវឌ្ឍរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ប្រធានបទមួយដែលមានការចាប់អារម្មណ៍ច្រើនជាងគេនិងជាចំណុចផ្ដោតនៃការពិភាក្សាក្នុងអត្ថបទនេះគឺភាពមិនស៊ីគ្នារវាងតម្រូវការចាំបាច់នៅមូលដ្ឋាន ដែលកំណត់ឡើងដោយក្រុមប្រឹក្សាឃុំ និងអាទិភាពរបស់ក្រុមប្រឹក្សាស្រុកក្នុងការអភិវឌ្ឍ។ អត្ថបទនេះចែកចេញជា៣ផ្នែក៖ ផ្នែកទី១ ពិពណ៌នាពីតម្រូវការជាក់ស្ដែងរបស់ប្រជាពលរដ្ឋនៅក្នុងឃុំ។ ផ្នែកទី២ ផ្ដល់នូវបៀបវារៈក្នុងការអភិវឌ្ឍរបស់ក្រុមប្រឹក្សាស្រុក និងការលំបាកផ្សេងៗដែលធ្វើឲ្យខ្លួន មិនអាចឆ្លើយតបបានទៅតាមតម្រូវការរបស់ក្រុមប្រឹក្សាឃុំ ហើយផ្នែកទី៣ បង្ហាញពីកង្វះខាតមួយចំនួនដែលត្រូវដោះស្រាយសម្រាប់ការអភិវឌ្ឍថ្នាក់ក្រោមជាតិនាពេលអនាគត។

## ផ្នែកទី១៖ តម្រូវការជាក់ស្ដែងរបស់ក្រុមប្រឹក្សាឃុំ

តម្រូវការចាំបាច់ជាក់ស្ដែងមួយចំនួន របស់ប្រជាពលរដ្ឋនៅតាមឃុំ រួមមាន៖ សេវាសាធារណៈចាំបាច់ជាមូលដ្ឋានក្នុងវិស័យអប់រំ សុខភាពសាធារណៈ និងសេវាបន្ទាប់បន្សំដទៃទៀត ដូចជា ការអភិរក្សធនធានធម្មជាតិ និងសមភាពយេនឌ័រ ជាដើម។

ក្រៅពីសមិទ្ធផលមួយចំនួន[២] ដែលឃុំសម្រេចបានក្នុងវិស័យអប់រំ និងសុខាភិបាល នៅមានបញ្ហាជាច្រើនទៀតដែលឃុំកំពុងជួបប្រទះដូចជា កង្វះខាតសាលារៀននៅតាមទីជនបទ និងមត្តេយ្យសហគមន៍ ការមិនយកចិត្តទុកដាក់និងអវត្តមានជាញឹកញាប់របស់គ្រូបង្រៀន កង្វះខាតមណ្ឌលសុខភាព សម្ភារៈបរិក្ខារពេទ្យ ឱសថ និងគិលានុបដ្ឋាក កង្វះខាតការយកចិត្តទុកដាក់ថែទាំអ្នកជំងឺ និងការគោរពក្រមសីលធម៌ក្នុងវិជ្ជាជីវៈពេទ្យជាដើម។ ក្រុមប្រឹក្សាឃុំ បានសំណូមពរឲ្យមានការសាងសង់សាលារៀន និងមត្តេយ្យសហគមន៍បន្ថែមសម្រាប់កុមារតាមទីជនបទ និងការពង្រឹងវិន័យវត្តមាន និងការយកចិត្តទុកដាក់របស់គ្រូបង្រៀន។ ក្នុងវិស័យសុខាភិបាលវិញ ខាងឃុំបានសំណូមពរឲ្យមានមណ្ឌលសុខភាពមួយសម្រាប់មួយឃុំ ការផ្ដល់ឲ្យបានច្រើនថែមទៀតនូវឱសថ សម្ភារៈបរិក្ខារពេទ្យ និងបុគ្គលិកថែទាំ ការពង្រឹងការគោរពក្រមសីលធម៌ពេទ្យ ការយកចិត្តទុកដាក់ថែទាំអ្នកជំងឺ និងការផ្សព្វផ្សាយព័ត៌មានពីសុខភាពស្ត្រី និងកុមារឲ្យបានកាន់តែទូលំទូលាយ។

ក្នុងវិស័យធនធានធម្មជាតិ និងសមភាពយេនឌ័រ ឃុំក៏បានធ្វើការងារជាច្រើនដែរ[៣]។ ទោះបីជាដូច្នោះក្ដី ឃុំបានសំណូមពរឲ្យខ្លួនមានសិទ្ធិក្នុងការដោះស្រាយជម្លោះ និងទប់ស្កាត់បទល្មើសមួយចំនួន ដែលប៉ះពាល់ដល់ផលប្រយោជន៍របស់ប្រជាពលរដ្ឋក្នុងឃុំ ដូចជា ការនេសាទខុសច្បាប់ ការឆ្ការព្រៃ ការកាប់បំផ្លាញព្រៃលិចទឹក និងការរំលោភយកដីប្រជាពលរដ្ឋពីសំណាក់អ្នកមានអំណាចយកធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន។ល។ ក្នុងវិស័យយេនឌ័រ ដោយសារចំនួនស្ត្រី និងកុមារនៅតាមសាលារៀនបន្តធ្លាក់ចុះ ហើយចំនួនស្ត្រីចូលប្រឡូកក្នុងឆាកនយោបាយ ក៏មិនទាន់មានច្រើនគ្រប់គ្រាន់ ក្រុមប្រឹក្សាឃុំបានស្នើដល់ក្រុមប្រឹក្សាខេត្ត/ស្រុក ក៏ដូចជាមន្ទីរជំនាញ ឲ្យជួយដល់គណៈកម្មាធិការស្ត្រី និងកុមាររបស់ឃុំ ដើម្បីសម្រួលឲ្យមានការផ្ដល់បានឆាប់រហ័សនូវហិរញ្ញវត្ថុសម្រាប់ការចំណាយលើបញ្ហាស្ត្រី និងការបញ្ជូនមន្ត្រីបច្ចេកទេសមកចូលរួមប្រជុំជាមួយគណៈកម្មាធិការនេះឲ្យបានញឹកញាប់។

## ផ្នែកទី២៖ របៀបវារៈនៃការអភិវឌ្ឍរបស់ក្រុមប្រឹក្សាស្រុក

ផែនការអនុវត្តរយៈពេលបីឆ្នាំដំបូង (IP3) (២០១០-២០១២) ក្នុងកម្មវិធីជាតិរយៈពេល១០ឆ្នាំសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិបានកំណត់ថា ក្រុមប្រឹក្សាស្រុកជាស្ថាប័នទទួលខុសត្រូវលើ ការផ្ដល់សេវាសាធារណៈ និងគាំទ្រដល់ក្រុមប្រឹក្សាឃុំ។ ប៉ុន្តែតាមភាពជាក់ស្ដែង ក្រុមប្រឹក្សាស្រុក មិនអាចបំពេញតាមតម្រូវការទាំងអស់របស់ឃុំបានទេ។ គម្រោងអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ស្រុកដែលមានទាំងផែនការអភិវឌ្ឍន៍ឃុំផងនោះ បានឆ្លុះបញ្ចាំងថា ក្រុមប្រឹក្សាស្រុកតែងផ្ដល់អាទិភាពលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ដូចជា ការសាងសង់ផ្លូវថ្នល់ជាដើម។ ចំណែកឯការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអរូបវ័ន្ត ដូចជា ការផ្ដល់សេវាអប់រំ និងសុខភាពដែលឃុំបានស្នើឡើងតាមរយៈផែនការអភិវឌ្ឍរបស់ខ្លួននោះ បែរជាទទួលបានការយកចិត្តទុកដាក់តិចតួច។

---

[១] អត្ថបទនេះ រៀបរៀងដោយលោក គ្រុយ វីរៈ អ្នកស្រាវជ្រាវ និងលោក ប៉ក់ គីមជឿន អ្នកស្រាវជ្រាវជាន់ខ្ពស់ នៅ CDRI ដោយមានការចូលរួមជាមតិយោបល់ពីបុគ្គលិកដទៃទៀតនៃ កម្មវិធីអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងកំណែទម្រង់សាធារណៈ។

[២] ឃុំបានចុះស្រង់ស្ថិតិកុមារអាយុ ៣-៦ឆ្នាំ ដែលត្រូវចូលរៀន និងកុមារបានបោះបង់ការសិក្សា បានផ្ដល់ជាថវិកាមួយចំនួន ដើម្បីឲ្យកុមារទាំងនោះបានបន្តការរៀនសូត្រ និងលើកទឹកចិត្តឪពុកម្ដាយឲ្យគិតគូរដល់ផលប្រយោជន៍នៃការសិក្សាចំពោះកូន។ ជាការរួមចំណែកក្នុងវិស័យសុខាភិបាល ឃុំបានផ្ដល់សម្ភារៈបរិក្ខារខ្លះៗ ការសាងសង់អាគារសម្រាប់ការពិនិត្យថែទាំសុខភាពស្ត្រី នៅមុន និងក្រោយពេលឆ្លងទន្លេ ការផ្សព្វផ្សាយព័ត៌មានឲ្យឪពុកម្ដាយយកកូនទៅចាក់ថ្នាំបង្ការ និងឲ្យស្ត្រីទៅពិនិត្យសុខភាពនិងសម្រាលកូន នៅមណ្ឌលសុខភាព។

[៣] ឃុំបានធ្វើការផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋ។ ក្នុងវិស័យសមភាពយេនឌ័រ ឃុំបានប្រមូលទិន្នន័យពីសុខភាព និងការអប់រំរបស់ស្ត្រី និងកុមារ និងធ្វើការពិនិត្យតាមដាននិងវាយតម្លៃសកម្មភាពយេនឌ័រ។

ក្រុមប្រឹក្សាស្រុកមានការលំបាកមួយចំនួន ទាក់ទិននឹងបញ្ហានេះ។ កង្វះខាតថវិកាជាការលំបាកមួយយ៉ាងធំ ដែលក្រុមប្រឹក្សាស្រុកកំពុងជួបប្រទះ។ មកទល់ពេលនេះ ក្រុមប្រឹក្សាស្រុកមិនដែលមានថវិកាអភិវឌ្ឍន៍អ្វី ក្រៅពីកញ្ចប់ថវិកាតាមគម្រោងតូចៗ ដូចជា គម្រោងមួយឈ្មោះថា គំនិតផ្ដួចផ្ដើមថ្នាក់ស្រុក[៤] នោះទេ។ ម្យ៉ាងទៀត IP3 ក៏បានចែងថា រដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ រួមទាំងក្រុមប្រឹក្សាស្រុកផង នឹងមិនអាចទទួលបានកញ្ចប់ថវិកាស្រុក/ក្រុងទេ លុះត្រាតែបានធ្វើផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ( RGC 2009, Pak *et al,* 2011 )។

ការបែងចែកតួនាទី និងការទទួលខុសត្រូវមិនច្បាស់លាស់ រវាងក្រុមប្រឹក្សាឃុំ និងស្រុក បាននាំឲ្យមានអាទិភាពអភិវឌ្ឍន៍ខុសគ្នា។ ក្រុមប្រឹក្សាស្រុកនៅតែយល់ថា ការផ្ដោតអាទិភាពអភិវឌ្ឍន៍ទៅលើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ គ្មានអ្វីខុសទេ ពីព្រោះខ្លួនមានការទទួលខុសត្រូវជាលក្ខណៈអន្តរឃុំ និងធំធេងជាង ក្រុមប្រឹក្សាឃុំដែលមានតែប្រជាជនក្នុងឃុំមួយរបស់ខ្លួន។ ម្យ៉ាងទៀត ការផ្ដល់សេវាសង្គមក្នុងវិស័យអប់រំ និងសុខាភិបាលនោះ គឺជាតួនាទី និងការទទួលខុសត្រូវរបស់មន្ទីរ និងការិយាល័យជំនាញ ហើយមិនមែនជាតួនាទីរបស់ក្រុមប្រឹក្សាស្រុកទេ។

កង្វះទំនាក់ទំនងរវាងក្រុមប្រឹក្សាទាំងពីរ ក៏ជាកត្តានាំឲ្យមានការកំណត់អាទិភាពអភិវឌ្ឍន៍ខុសគ្នាដែរ។ របាយការណ៍អង្កេតពិសេសមួយស្ដីពីការស្វែងយល់ឲ្យបានស៊ីជម្រៅពី កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ( Chheat *etal,* 2011 ) និងការសិក្សាស្ដីពីកំណែទម្រង់វិមជ្ឈការនៅថ្នាក់ស្រុក/ក្រុង ( Pak *etal,*2011 ) សុទ្ធតែបង្ហាញច្បាស់ថា ទំនាក់ទំនងរវាងក្រុមប្រឹក្សាទាំងពីរនេះនៅមានតិចតួច។

ខ្សែគណនេយ្យភាព រវាងក្រុមប្រឹក្សាឃុំ និងស្រុក នៅមិនទាន់ច្បាស់លាស់។ កិច្ចពិភាក្សារបស់សិក្ខាសាលាបានបង្ហាញថា ចំពោះថ្នាក់ក្រោម អ្នកដែលស្រុកយល់ថា ខ្លួនត្រូវមានគណនេយ្យភាព គឺប្រជាជន ហើយចំពោះថ្នាក់លើវិញ ស្ថាប័នដែលស្រុកយល់ថា ខ្លួនត្រូវមានគណនេយ្យភាពគឺ ក្រុមប្រឹក្សាខេត្ត និងក្រសួងមហាផ្ទៃ។ ការយល់ឃើញបែបនេះក៏មានបញ្ជាក់ផងដែរ នៅក្នុងរបាយការណ៍អង្កេតពិសេសមួយ ស្ដីពីការស្វែងយល់ឲ្យបានស៊ីជម្រៅពី កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ( Chheat *et al,* 2011 )។ តើទស្សនៈអំពីខ្សែគណនេយ្យភាព និងទំនាក់ទំនងដូចខាងលើ មានឫសគល់មកពីណា ?

តាំងពីដើមរៀងមក ប្រព័ន្ធរដ្ឋបាលខ្មែរ មានការប្រមូលផ្ដុំអំណាចនៅថ្នាក់មជ្ឈឹម ហើយពោរពេញទៅដោយឋានានុក្រមដែលបន្តមករហូតយ៉ាងហោចណាស់ ក៏ដល់ការបោះឆ្នោតឆ្នាំ១៩៩៣ ដែរ (Kim & Öjendal 2008)។ តាមប្រពៃណីនេះ មន្ត្រីថ្នាក់ស្រុកក៏បន្តអនុវត្តតាមឋានានុក្រមខាងលើ ហើយមានគណនេយ្យភាពតែចំពោះថ្នាក់ខេត្ត និងគណបក្សកាន់អំណាចប៉ុណ្ណោះ។ ក្រុមប្រឹក្សាស្រុក ស្ទើរតែមិនមានគណនេយ្យភាពចំពោះថ្នាក់ឃុំទេ ( ibid )។ ការសិក្សាដដែលបញ្ជាក់ទៀតថា ៨១,៨១% នៃមន្ត្រីថ្នាក់ស្រុកគិតថា ពួកខ្លួនជាចៅហ្វាយនាយរបស់មន្ត្រីឃុំ និងមានតែ ២,៥៩% ប៉ុណ្ណោះ ដែលគិតថា ពួកខ្លួនត្រូវមានគណនេយ្យភាពចំពោះ ឃុំ ( ibid, p 27 )។

ជារួម បញ្ហាថ្នាក់ស្រុកមិនមានថវិកាអភិវឌ្ឍន៍ផ្ទាល់ខ្លួន និងថវិកាសម្រាប់គាំទ្រដល់ក្រុមប្រឹក្សាឃុំ ភាពមិនច្បាស់លាស់ក្នុងការបែងចែកមុខងារនិងការទទួលខុសត្រូវ រវាងក្រុមប្រឹក្សាទាំងពីរ ទំនាក់ទំនង និងខ្សែគណនេយ្យភាពមិនច្បាស់លាស់ ជាកត្តានាំឲ្យក្រុមប្រឹក្សាទាំងពីរ មានអាទិភាពអភិវឌ្ឍន៍មិនស៊ីគ្នា ហើយកង្វះខាតមួយចំនួន ក៏បានផុសឡើងពីភាពមិនស៊ីគ្នានេះ។

## ផ្នែកទី៣៖ កង្វះខាតត្រូវដោះស្រាយសម្រាប់ការអភិវឌ្ឍនាពេលអនាគត

ការពិពណ៌នាពីភាពមិនស៊ីគ្នា រវាងតម្រូវការអភិវឌ្ឍន៍របស់ក្រុមប្រឹក្សាឃុំនិងស្រុកខាងលើបានបង្ហាញថា នៅមានកង្វះខាតមួយចំនួនដែលរដ្ឋាភិបាលត្រូវដោះស្រាយ ដើម្បីធានាឲ្យមានការអភិវឌ្ឍនៅថ្នាក់ក្រោមជាតិ ពិតប្រាកដមួយនាពេលអនាគត។

ដើម្បីអាចបំពេញបានតាមតួនាទីរបស់ខ្លួន ដែលមានចែងក្នុង IP3 នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្នុងការផ្ដល់សេវា និងការគាំទ្រដល់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាស្រុកត្រូវការជាចាំបាច់នូវកញ្ចប់ថវិកាអភិវឌ្ឍន៍ក្នុងទម្រង់បែបណាមួយពីរដ្ឋាភិបាល ដើម្បីឲ្យខ្លួនមានលទ្ធភាពធ្វើផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ហើយឈានទៅដល់សិទ្ធិទទួលបានកញ្ចប់ថវិកាស្រុក/ក្រុង។

កញ្ចប់ថវិកាស្រុក/ក្រុងនេះ ក៏ជាប់ពាក់ព័ន្ធនឹងតួនាទីមុខងារច្បាស់លាស់ដែលក្រុមប្រឹក្សាស្រុក និងឃុំត្រូវអនុវត្ត។ ក្រុមប្រឹក្សាស្រុកមិនអាចអនុវត្តបានពេញលេញទេនូវមុខងារ និងការទទួលខុសត្រូវជាផ្លូវការរបស់ខ្លួន ប្រសិនបើមិនមានកញ្ចប់ថវិកាស្រុក/ក្រុងនោះ។ ការបែងចែកតួនាទី និងការទទួលខុសត្រូវ និងការកំណត់ខ្សែគណនេយ្យភាពរវាងក្រុមប្រឹក្សាឃុំ និងស្រុកមិនទាន់ច្បាស់លាស់ នឹងបន្តរាំងស្ទះដល់ដំណើរការ និងសមត្ថភាពអនុវត្តផែនការអភិវឌ្ឍន៍ និងការផ្ដល់សេវាជាបន្តទៀត។

ដើម្បីបង្កើនការយល់ដឹងពីតួនាទី និងការទទួលខុសត្រូវរៀងៗខ្លួនឲ្យកាន់តែច្បាស់ ក្រុមប្រឹក្សាឃុំ និងស្រុក ក៏ត្រូវការជាចាំបាច់នូវការបណ្ដុះបណ្ដាល និងការផ្សព្វផ្សាយបន្ថែមស្ដីពីតួនាទី និងការទទួលខុសត្រូវដែលមានចែងក្នុងច្បាប់រៀបចំអង្គការ។

សព្វថ្ងៃគេមិនទាន់ដឹងច្បាស់ទេថា តើការបង្កើតសមាគមក្រុមប្រឹក្សា[៥] នាពេលខាងមុខ នឹងអាចជួយឲ្យក្រុមប្រឹក្សាឃុំ និងស្រុកបន្សុីគ្នាបាននូវ អាទិភាពនៃតម្រូវការអភិវឌ្ឍន៍ដែលខុសគ្នារបស់ខ្លួន ព្រមទាំងបង្កើនទំនាក់ទំនងទៅវិញទៅមកឲ្យបានកាន់តែជិតស្និទ្ធ ដើម្បីអាចឆ្លើយតបបានកាន់តែប្រសើរទៅនឹងតម្រូវការចាំបាច់របស់ប្រជាពលរដ្ឋក្នុងឃុំ។

## ឯកសារយោងមាននៅក្នុងអត្ថបទជាភាសាអង់គ្លេស

[៤] គម្រោងគំនិតផ្ដួចផ្ដើមស្រុកនេះ ក្រសួងមហាផ្ទៃ បានបង្កើតឡើងក្នុងឆ្នាំ ២០០៦ ដោយមានជំនួយពីគម្រោងគាំទ្រការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈគម្រោងវិមជ្ឈការ និងវិសហមជ្ឈការ និងគម្រោងគ្រប់គ្រងធនធានធម្មជាតិ និងជីវភាព ( NCDD 2009 )។

[៥] នៅឯសិក្ខាសាលាលើកទី៧ នៃសម្ព័ន្ធភាពជាតិឃុំ/សង្កាត់ ដែលបានធ្វើនៅថ្ងៃទី២៩ វិច្ឆិកា ២០១១ មានការឯកភាពគ្នាលើការបង្កើតឲ្យមានសមាគមក្រុមប្រឹក្សាថ្នាក់ក្រោមជាតិចំនួនពីរគឺ ១) សមាគមក្រុមប្រឹក្សាសម្រាប់ថ្នាក់រាជធានី និងខេត្ត និង ២) សមាគមក្រុមប្រឹក្សាក្រុង/ស្រុក/ខណ្ឌ និងឃុំ/សង្កាត់។